# មើលទង់ជ័យពុទ្ធសាសនា ឃើញទង់ជាតិកម្ពុជាក្រោម

**អត្ថបទវិភាគរបស់វិទ្យុសំឡេងកម្ពុជាក្រោម**
ចេញផ្សាយថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០១៧
**ដោយ ថាច់ ប្រីជា គឿន**

នៅថ្ងៃទី ៧, ៨ និងទី ៩ ខែកុម្ភៈ ឆ្នាំ ២០១៧ កន្លងទៅនេះ គណៈមន្ត្រីសង្ឃខេត្តព្រះត្រពាំង បានចាត់តាំងកម្មវិធីប្រឡងរួមខេត្ត បញ្ចប់ថ្នាក់ពុទ្ធិកសិក្សាបឋមភូមិ និងទុតិយភូមិ នាវត្តតាលភិរិឧត្តុង្គមានជ័យសេរីវង្សារាម (រំដួល) ឋិតនៅក្នុងស្រុកថ្កូវ ខេត្តព្រះត្រពាំង ។ ឆ្នាំសិក្សាពុទ្ធសករាជ ២៥៦០ គ្រឹស្តសករាជ ២០១៦-២០១៧ នេះ វត្តរំដួលបានធ្វើជាម្ចាស់ផ្ទះ ក្នុងការរៀបចំមណ្ឌលប្រឡងសម្រាប់ទទួលសមណសិស្ស និងសិស្សប្រុសស្រីដែលជាយុវជនមកពីវត្តនានានៅក្នុងខេត្តព្រះត្រពាំង ។ កម្មវិធីនេះ គណៈកម្មការរៀបចំមណ្ឌលប្រឡងបានរៀបចំ និងតុបតែងវេទិកាប្រកាសលទ្ធផលយ៉ាងស្រស់ស្អាតប្រកបលក្ខណៈជាតិ និងសាសនា ដែលមានទ្រង់ទ្រាយប្រាសាទបន្ទាយស្រី ហើយមានដាក់ទង់ជ័យពុទ្ធសាសនានៅចំកណ្តាលវេទិកា បានធ្វើឱ្យរំលេចនូវពណ៌ ខៀវ លឿង ក្រហម ដែលជាពណ៌នៃទង់ជាតិកម្ពុជាក្រោមយ៉ាងច្បាស់ក្រឡែតគួរជាទីមោទនៈពន់ពេក ។ ពេលបានឃើញរូបភាពនៃវេទិកាប្រកាសលទ្ធផលមនុស្សម្នារំភើបចិត្តគ្រប់គ្នា ប៉ុន្តែក្រោយមកមានព័ត៌មានតាមបណ្តាញសង្គម Facebook ផ្សាយថា មានមនុស្សឱ្យរុះរើចេញដោយសារវេទិកានេះ មើលទៅឃើញទង់ជាតិកម្ពុជាក្រោមច្បាស់ពេក បណ្តាលឱ្យមន្ត្រីសង្ឃគ្រប់អង្គមិនហ៊ានឡើងគង់នៅលើវេទិកានេះ ហើយនាំគ្នាគង់នៅខាងក្រោមមុខវេទិកាវិញ ព្រោះខ្លាចរដ្ឋាភិបាលយួនចោទប្រកាន់បញ្ហាផ្សេងៗជាដើម ។ ក្រោយមក គណៈកម្មការរៀបចំបានរើតុផ្កាសម្រាប់តម្កល់ពុទ្ធបដិមាចេញពីមុខទង់ជ័យពុទ្ធសាសនា ដើម្បីឱ្យមើលឃើញច្បាស់ ពណ៌ទាំង ៦ នៃទង់ជ័យពុទ្ធសាសនា គឺ ខៀវ លឿង ក្រហម ស ហង្សបាទ និងពណ៌ភ្លឺផ្លេក ទើបមន្ត្រីសង្ឃហ៊ានឡើងគង់លើវេទិកានោះ ។

តើការណ៍ដែលគណៈមន្ត្រីសង្ឃខ្លាចពណ៌ ខៀវ លឿង ក្រហម នេះ វាមានអត្ថន័យយ៉ាងណាសម្រាប់ "**សិទ្ធិសម្រេចវាសនាខ្លួនដោយឯង**" របស់ប្រជាជាតិខ្មែរក្រោមនៅដែនដីកម្ពុជាក្រោម នាពេលបច្ចុប្បន្ន និងអនាគត ?

**ខ្មែរក្រោមនៅមិនទាន់មានសិទ្ធិពេញលេញក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួន**

ទង់ជាតិកម្ពុជាក្រោម មានការទទួលស្គាល់ពីសំណាក់ខ្មែរក្រោមទូទាំងពិភពលោក និងពីអង្គការប្រជាជាតិគ្មានតំណាង (UNPO) បន្ទាប់ពីសហព័ន្ធខ្មែរកម្ពុជាក្រោម បាន

ចូលជាសមាជិកនៃអង្គការមួយនេះ កាលពីថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០១ មក ។ សព្វថ្ងៃ ទង់ជាតិកម្ពុជាក្រោមប្រជាជាតិខ្មែរក្រោមនៅក្រៅប្រទេសទូទាំងពិភពលោក ដូចជា សហរដ្ឋអាមេរិក កាណាដា អូស្ត្រាលី នីវ-ស៊ីឡែន ប្រទេសនៅអឺរ៉ុប កម្ពុជា និង ថៃ ជាដើម មានសិទ្ធិពេលលេញក្នុងការប្រើប្រាស់ជាផ្លូវការ ដោយមិនមានរដ្ឋាភិបាល ឬ បុគ្គលណាម្នាក់ហាមឃាត់ឡើយ ។ ផ្ទុយទៅវិញ ទង់ជាតិកម្ពុជាក្រោមជាតំណាងជាតិខ្មែរក្រោម បែរជាមិនមានសិទ្ធិបង្ហូតឡើងនៅលើដែនដីកម្ពុជាក្រោមរបស់ខ្លួនទៅវិញ ។ ម្យ៉ាងទៀត សូម្បីតែទង់ជ័យពុទ្ធសាសនាសោះ ដែលមានពណ៌ ខៀវ លឿង និង ក្រហម ជាពណ៌នៃទង់ជាតិកម្ពុជាក្រោម ក៏បានធ្វើឱ្យគណៈមន្ត្រីសង្ឃខ្មែរខ្លះ នៅខេត្តព្រះត្រពាំង ខ្លាចផងដែរ ។ នេះឆ្លុះបញ្ចាំងឱ្យឃើញថា ទម្ងន់នៃការគាបសង្កត់របស់រដ្ឋាភិបាលបក្សកុម្មុយនិស្តយួនលើជនជាតិដើមខ្មែរក្រោម នៅតែធ្ងន់សាហៅយង់ឃ្នងដដែល ។

ដោយសារទ្រាំលែងបាននឹងការឈឺចាប់ ព្រោះបានឃើញប្រជាជាតិខ្មែរក្រោមកំពុងតែរស់នៅក្នុងភាពភ័យខ្លាចរងទុក្ខខ្លោចផ្សានៅក្រោមនឹងអាណានិគមយួននោះ ព្រះសង្ឃមួយអង្គបានសរសេរអត្ថបទកំណាព្យមួយមានចំណងជើងថា “**វេទិកាអភ័ព្វ**” ហើយបង្ហោះនៅលើបណ្តាញសង្គម Facebook ដើម្បីសម្តែងពីព្រះទ័យព្រួយបារម្ភរបស់ព្រះអង្គចំពោះទង្វើដែលបុគ្គលមន្ត្រីសង្ឃខេត្តអង្គខ្លះបានបញ្ជាឱ្យរុះរើវេទិកានោះចេញ ។ កំណាព្យនោះមានសេចក្តីថា៖

***“វេទិកាល្អស្រស់សម្រស់មានជ័យ***
***តែបាត់សេរីអប្រិយកំព្រា***
***ពណ៌ស្រស់ឆើតឆាយប្រាយប្រាប់វាល់គ្នា***
***វេទិការងាមានញៀវនឹងពណ៌ ។***
***ខៀវលឿងក្រហមសហង្សបាទនិងផ្លែក***
***តែអ្នកមានភ្នែកមើលខ្មៅជាស***
***ឃើញបានតែបីនាំឱ្យវឹកវរ***
***ថាទង់មិនល្អថាខុសអាស្នា “[1]” ។***
***វេទិកាបានគេតុបតែងចែងចាំងសមរម្យ***
***តែទាស់អ្នកធំឱ្យរើឱ្យសា***

[1] **អាសនៈ** កន្លែងអង្គុយ, ទីអង្គុយ ។

*កន្លែងឱ្យគង់ទ្រង់មិនជ្រះថ្លា*
*បែរយកហេតុការណ៍ថាលើក្តៅពេក ។*
*នាំគ្នាចុះគង់លង់ក្រោមទាំងអស់*
*ចោលវេទិកាស្រស់ច្រាល់ពណ៌ភ្លឺផ្លេក*
*កូនចៅបៀមមាត់សង្កត់ទឹកភ្នែក*
*បេះដូងស្ទើរបែកស្តាយខ្លួនជាខ្មែរ ។*
*វេទិកាអូនអើយកុំឡើយសោកា*
*កុំយំជីវ៉ាបាសួនមាសស្នេហ៍*
*គេស្អប់អ្នកហើយត្រាណត្រើយមាសមេ*
*អភ័ព្វម្ល៉េះទេវេទិកាវំដួល ៕ ៚*

រដ្ឋាភិបាលយួនជាប្រទេសហត្ថលេខីមួយ បានចុះហត្ថលេខាលើសេចក្តីប្រកាសជាសកលនៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមកាលពីឆ្នាំ ២០០៧ ដោយបានសន្យាថា នឹងផ្តល់សិទ្ធិដល់ជនជាតិដើមគ្រប់រូបនៅក្នុងប្រទេសវៀតណាម ក្នុងនោះមានខ្មែរក្រោមនៃដែនដីកម្ពុជាក្រោមផងដែរ ឱ្យបានទទួលនូវសិទ្ធិជាមូលដ្ឋានរបស់ខ្លួនដោយគ្មានការគំរាមកំហែងពីសំណាក់អាជ្ញាធរឡើយ ។ ផ្ទុយទៅវិញសេចក្តីប្រកាសជាសកល នៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្សចំនួន ៣០ មាត្រា និងសិទ្ធិជនជាតិដើមចំនួន ៤៦ មាត្រា ក្នុងនោះមានមាត្រាចែងអំពី “**សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង**” ជាដើម មិនត្រូវបានរដ្ឋាភិបាលយួនអនុវត្តតាមឡើយ ហើយរដ្ឋាភិបាលយួនមានតែការគំរាមកំហែង និងធ្វើទុក្ខបុកម្នេញលើជនជាតិដើមខ្មែរក្រោមកាន់តែខ្លាំងជាងមុន ថែមទៀត ។

**ខ្យល់ "សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង" បានបក់ដល់កម្ពុជាក្រោម៖**

ទោះបី គណៈមន្ត្រីសង្ឃនៅកម្ពុជាក្រោម និងពលរដ្ឋខ្មែរក្រោមខ្លះនៅមានការខ្លាចចំពោះទង់ជាតិកម្ពុជាក្រោម យ៉ាងណាក៏ដោយ តែវាជាចំណុចវិជ្ជមានមួយ នៃការតស៊ូមតិរបស់សហព័ន្ធខ្មែរកម្ពុជាក្រោមនៅក្រៅប្រទេសរយៈពេល ២០ ឆ្នាំកន្លងមកនេះ បានធ្វើឱ្យអន្តរជាតិ ពលរដ្ឋខ្មែរនៅប្រទេសកម្ពុជា និងប្រជាជាតិខ្មែរក្រោមនៅដែនដីកម្ពុជាក្រោម បានដឹងយ៉ាងច្បាស់អំពីទង់ជាតិរបស់ខ្លួន ។

កាលពី ២៣ ឆ្នាំមុន គឺនៅខែធ្នូ ឆ្នាំ ១៩៩៤ ថ្នាក់ដឹកនាំសហព័ន្ធខ្មែរកម្ពុជាក្រោម បានប្រជុំគ្នានៅ Tampa រដ្ឋ Florida សហរដ្ឋអាមេរិក ដើម្បីបង្កើតទង់ជាតិកម្ពុជាក្រោម ហើយ ៧ ឆ្នាំក្រោយមក គឺនៅថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០១ អង្គការប្រជាជាតិគ្មាន

តំណាងហៅកាត់ថា UNPO បានទទួលស្គាល់ទង់ជាតិកម្ពុជាក្រោមជាផ្លូវការ ស្របពេលដែលអង្គការនេះបានទទួលស្គាល់សហព័ន្ធខ្មែរកម្ពុជាក្រោម ជាសមាជិកពេញសិទ្ធិរបស់ខ្លួន នាទីក្រុង Philadelphia សហរដ្ឋអាមេរិក ។ កាលពី ២៣ ឆ្នាំមុន ក្រៅពីសមាជិកនៃសហព័ន្ធខ្មែរកម្ពុជាក្រោម មិនសូវមាននរណាបានដឹងថា ខ្មែរក្រោមមានទង់ជាតិរបស់ខ្លួនឡើយ ប៉ុន្តែបន្ទាប់ពីសហព័ន្ធខ្មែរកម្ពុជាក្រោមធ្វើការតស៊ូមតិនៅលើឆាកអន្តរជាតិ និងព្យាយាមផ្សព្វផ្សាយនូវសកម្មភាពរបស់ខ្លួន តាមរយៈវិទ្យុ ទូរទស្សន៍ ព្រឹត្តិបត្រ កាសែត ស៊ីឌី (CD) ចម្រៀងជាតិនិយម ល្ខោននិយាយរឿង ចៅហ្វាយ គុយ វីស៊ីឌី (VCD) និងឌីវីឌី (DVD) ទៅដល់ដែនដីកម្ពុជាក្រោមជាបន្តបន្ទាប់ ហើយប្រជាពលរដ្ឋខ្មែរក្រោមបាននាំគ្នាគាំទ្រជ្រោងទង់ជាតិរបស់ខ្លួនឡើងនៅគ្រប់ទីកន្លែងក្នុងពិភពលោក ក្នុងនោះ មានការធ្វើបាតុកម្ម ជាដើម បានធ្វើឱ្យពលរដ្ឋខ្មែរក្រោមនៅក្នុងស្រុក បានស្គាល់នូវទង់ជាតិរបស់ខ្លួន បានឮពាក្យ "**សិទ្ធិមនុស្ស**" និងជាពិសេសបានឮពាក្យថា "**សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង**" ជាគោលដៅមួយ ដែលសហព័ន្ធខ្មែរកម្ពុជាក្រោមកំពុងតែធ្វើដំណើរឆ្ពោះទៅកាន់មាតុភូមិកម្ពុជាក្រោម សព្វថ្ងៃ ។ ពីមុន ពេលដែលពលរដ្ឋខ្មែរក្រោមនៅក្នុងស្រុកមិនទាន់មានអិនធើណិត និង Facebook នោះ សហព័ន្ធខ្មែរកម្ពុជាក្រោមបានព្យាយាមរកគ្រប់មធ្យោបាយក្នុងការបញ្ជូនព័ត៌មានរបស់ខ្លួនទៅដែនដីកម្ពុជាក្រោម តាមរយៈច្រកព្រំដែននៃប្រទេសកម្ពុជា ដើម្បីឱ្យពលរដ្ឋខ្មែរក្រោមបានជ្រាប ។ មកដល់ឆ្នាំ ២០១៧ នេះ លទ្ធផលនៃការតស៊ូនោះទទួលបានផ្លែផ្កាគួរឱ្យកត់សម្គាល់ ។ ផ្លែផ្កាដែលយើងបាន និងកំពុងតែមើលឃើញនោះ គឺប៉ុន្មានឆ្នាំមកនេះ រដ្ឋាភិបាលយួនបានចាប់ផ្តើមផ្អើលនឹងពណ៌ ខៀវ លឿង ក្រហម ហើយដើរគំរាមព្រះសង្ឃខ្មែរក្រោមគ្រប់ទីកន្លែង ។ ម៉្យាងទៀត ពិធីប្រឡងយកសញ្ញាបត្រថ្នាក់ពុទ្ធិកវិទ្យាល័យបឋមភូមិ និងទុតិយភូមិ នៅខេត្តព្រះត្រពាំង កាលពីសប្តាហ៍កន្លងទៅនេះ គណៈមន្ត្រីសង្ឃបាននាំគ្នាចុះពីវេទិកាដោយសារផ្អើលនឹងពណ៌ ខៀវ លឿង ក្រហម នៅក្នុងទង់ជ័យពុទ្ធសាសនា ជាសញ្ញាមួយបញ្ជាក់ឱ្យឃើញថា មន្ត្រីសង្ឃ និងពលរដ្ឋខ្មែរក្រោមគ្រប់អង្គ និងរូបបានដឹងហើយថា ខ្មែរក្រោមខ្លួនឯងមានទង់ជាតិតំណាងជាតិខ្លួននឹងគេដែរ គឺមិនមែនទង់ពណ៌ក្រហមផ្កាយលឿងរបស់យួននោះទេ ។ ទោះបីពេលនេះពលរដ្ឋនៅក្នុងស្រុកខ្លះនៅផ្អើលនឹងទង់ជាតិរបស់ខ្លួនយ៉ាងណាក៏ដោយ តែសហព័ន្ធខ្មែរកម្ពុជាក្រោមបានទទួលជោគជ័យនៅលើដំណាក់កាលមួយ គឺបានធ្វើឱ្យពលរដ្ឋខ្មែរក្រោមក្នុងស្រុកបានដឹងអំពីអ្វី ដែលជាតិរបស់ខ្លួនចង់បាននាពេលអនាគតហើយ ។

ធម្មតា ការធ្វើបដិវត្តដើម្បីផ្តួលរំលំរបបផ្តាច់ការអ្វីមួយ ឬការតស៊ូមតិដើម្បីផ្លាស់ប្តូរសង្គមណាមួយ ឬក៏ការធ្វើចលនាដើម្បីផ្លាស់ប្តូរគំនិតអ្វីមួយ វាត្រូវចំណាយពេលវេលា

យូរណាស់ដើម្បីបានឈានដល់គោលដៅ ។ ដូចជាស្ថានភាពកម្ពុជាក្រោម សព្វថ្ងៃ ប្រជាជាតិខ្មែរក្រោមនៅក្នុងស្រុកកំពុងតែនៅក្រោមនឹមត្រួតត្រារបស់អាណានិគមយួន ហើយរដ្ឋាភិបាលយួនកំពុងតែលាងខួរក្បាលយុវជនខ្មែរក្រោមឱ្យភ្លេចនូវប្រវត្តិរបស់ខ្លួនតាមរយៈការសិក្សានៅតាមសាលារៀនយួន ដើម្បីធ្វើឱ្យកូនចៅខ្មែរក្រោមជំនាន់ក្រោយក្លាយទៅជាយួនតាមគំនិតរបស់ **ហូ ជី មិញ** ថា “**ដប់ឆ្នាំដាំដើមឈើ មួយរយឆ្នាំដាំមនុស្ស**” ។ ដូច្នេះដើម្បីបានឈានដល់គោលដៅ “**សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង**” នោះ គឺយើងត្រូវការប្រើពេលវេលាមួយសម្រាប់ធ្វើបដិវត្តផ្លាស់ប្តូរគំនិតយុវជន ព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោមគ្រប់រូបឱ្យប្តូរគំនិតពីការភ័យខ្លាចទៅជាក្លាហាន ក្នុងការប្រើប្រាស់នូវសិទ្ធិជាមូលដ្ឋានរបស់ខ្លួនស្របតាមច្បាប់ និងតាមសេចក្តីប្រកាសជាសកលស្តីពី **សិទ្ធិជនជាតិដើម** និង **សិទ្ធិមនុស្ស** របស់អង្គការសហប្រជាជាតិក្នុងនាមខ្លួនជាម្ចាស់ស្រុក នៃដែនដីកម្ពុជាក្រោមជាមុនសិន ។ ពេលដែលពលរដ្ឋខ្មែរក្រោមម្នាក់ៗបានស្គាល់នូវសិទ្ធិរបស់ខ្លួន និងបានស្គាល់នូវពង្សាវតាររបស់ខ្លួនហើយ ពួកគេនឹងហ៊ានធ្វើអ្វីគ្រប់យ៉ាងដើម្បីបុព្វហេតុការពារនូវជាតិរបស់ខ្លួនឱ្យបានគង់វង្សដោយមិនមានអំណាចអ្វីមកទប់ស្កាត់បានឡើយ ៕